# សូមទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូចខាងក្រោមនេះ (캄보디아어)

**<មុនមួយថ្ងៃ ពេលចាក់វ៉ាក់សាំង>**

**01.** ពិនិត្យសារណាំនាំអំពីការចាក់វ៉ាក់សាំងកូវីដ១៩

⊙ អ្នកនឹងទទួលបានសារណែនាំអំពីការកក់នៃការចាក់វ៉ាក់សាំងកូវីដ១៩
ហើយសូមពិនិត្យទីតាំងសម្រាប់ចាក់វ៉ាក់សាំង
និងពេលវេលាម្តងទៀត។

⊙ អាចនឹងមានភាពច្របូកច្របល់ ដូច្នេះសូមពិនិត្យមើលផ្លូវឬយានយន្តសាធារណៈ
ដើម្បីធ្វើដំណើរទៅដល់
ទីតាំងសម្រាប់ចាក់វ៉ាក់សាំង។

⊙ សម្រាប់ការចាក់វ៉ាក់សាំងនៅថ្ងៃស្អែក
ចូរពាក់អាវដែលងាយលាត់ដៃអាវដល់ខាងលើនៃដៃដែលត្រូវចាក់វ៉ាក់សាំង។

**<នៅថ្ងៃចាក់វ៉ាក់សាំង>**

**02.** មុនពេលចាកចេញពីផ្ទះ

⊙ ពិនិត្យមើលស្ថានភាពសុខភាពថ្ងៃនេះ។ ប្រសិនបើអ្នកក្តៅខ្លួន ការចាក់វ៉ាក់សាំងត្រូវពន្យារពេល។

⊙ ស្លៀកពាក់ខោអាវ និងពាក់ម៉ាស ដែលបានត្រៀមទុក ហើយចេញទៅទទួលការចាក់វ៉ាក់សាំង។

⊙ ត្រូវទៅដល់ ៣០នាទីមុនម៉ោងដែលបានកក់ទុក។

**03.** ពេលមកដល់ទីតាំងសម្រាប់ចាក់វ៉ាក់សាំង

⊙ នៅពេលអ្នកទៅដល់ទីតាំងសម្រាប់ចាក់វ៉ាក់សាំង សូមបង្ហាញអត្តសញ្ញាណប័ណ្ណ
ឬសារណែនាំអំពីការចាក់វ៉ាក់សាំងហើយ ពិនិត្យមើលពីការកក់នៃការចាក់វ៉ាក់សាំង។

⊙ បន្ទាប់ពីពិនិត្យមើលសីតុណ្ហភាពរាងកាយរបស់អ្នករួច សូមចូលបន្ទប់រង់ចាំការចាក់វ៉ាក់សាំង។

**04.** ការបំពេញតារាងធ្វើការពិនិត្យបឋម

⊙ ចូរបំពេញតារាងធ្វើការពិនិត្យបឋមទាំងអស់។

**05.** ធ្វើការពិនិត្យបឋម(ការពិគ្រោះរបស់គ្រូពេទ្យ)

⊙ ការពិគ្រោះជាមួយគ្រូពេទ្យធ្វើការពិនិត្យបឋម។

⊙ ការសាកសួរបញ្ហាដែលងឿងឆ្ងល់ អំពីការចាក់វ៉ាក់សាំងកូវីដ១៩។

**06.** ការចាក់វ៉ាក់សាំង

⊙ ទៅបន្ទប់ទទួលចាក់ថ្នាំបង្ការ ហើយទទួលការចាក់វ៉ាក់សាំងកូវីដ១៩។

**07.** ការរង់ចាំនៅបន្ទប់សង្កេត

⊙ បន្ទាប់ពីចាក់វ៉ាក់សាំងរួច សូមរង់ចាំនៅក្នុងបន្ទប់សង្កេតរយៈពេល ១៥ ទៅ ៣០នាទី ដើម្បីការពារការកើតឡើង
នប្រតិកម្មមិនល្អ។

**08.** ទៅផ្ទះ

⊙ ប្រសិនបើរង់ចាំនៅក្នុងបន្ទប់សង្កេតបានចប់ហើយ ចូរត្រឡប់ទៅផ្ទះវិញឱ្យបានតាមដែលអាចធ្វើទៅបាន និង កុំធ្វើការងារធ្ងន់ហួសប្រមាណ។

⊙ ចូរកត់សម្គាល់ទុកនៅលើប្រតិទិន កាលបរិច្ឆេទចាក់ចាក់វ៉ាក់សាំងលើកទី២ ដែលបានកំណត់។

**09.** នៅផ្ទះ

⊙ បន្ទាប់ពីការចាក់វ៉ាក់សាំង អាចកើតមានជាទូទៅរោគសញ្ញាដូចខាងក្រោម ហើយដែលជាប្រតិកម្មដែលអាចកើតឡើង ក្នុងកំឡុងពេលដំណើរការភាពស៊ាំត្រូវបានបង្កើតឡើង ភាគច្រើនបាត់ទៅវិញក្នុងរយៈពេល ២ ទៅ ៣ថ្ងៃ។

| | បង៉ែចក | កន្ទុលវៃចាក់វ៉ាក់សាំង | រាងកាយទាំងមូល |
|---|---|---|---|
| រោគសញ្ញាទូទៅ និងការព្យាបាលបន្ទាប់ពីការចាក់វ៉ាក់សាំង | រោគសញ្ញា | · ឈឺចុកចាប់<br>· ហើម | · គ្រុនក្តៅ · គ្រុនញាក់<br>· អស់កម្លាំង · ឈឺក្បាល |
| | ការព្យាបាល | · យកកន្សែងត្រជាក់ស្អាត ស្អំនៅកន្ទុលវៃនោះ។<br>· ធ្វើចលនាដៃ ឬលំហាត់ប្រាណដៃ | · ផឹកទឹកឱ្យបានច្រើន និងសម្រាកគ្រប់គ្រាន់<br>· ស្លៀកពាក់ខោអាវងាយៗ |
| | | · គ្មានការហាមឃាត់លើការប្រើប្រាស់ថ្នាំបំបាត់ការឈឺចាប់ ·ថ្នាំបញ្ចុះកំដៅទេ ប៉ុន្តែត្រូវបានណែនាំឱ្យប្រើថ្នាំដែលមានផ្ទុកអាសេតាមីណូហ្វេនេ ដែលគ្មានប្រសិទ្ធិភាពក្នុងការបំបាត់ការរលាក តាមដែលអាចធ្វើទៅបាន។ | · ចូរត្រៀមថ្នាំបំបាត់ការឈឺចាប់ ·ថ្នាំបញ្ចុះកំដៅទុកមុនពេលចាក់វ៉ាក់សាំង |

⊙ ភាគច្រើនអាការៈត្រូវបានប្រសើរឡើង ដោយការប្រើថ្នាំបញ្ចុះកំដៅ ·ថ្នាំបំបាត់ការឈឺចាប់ ប៉ុន្តែប្រសិនបើកន្ទុលវៃដែលចាក់ វ៉ាក់សាំងឡើងហើម, ឈឺចាប់, ក្រហម ផ្សេងៗបន្តលើសពី២ថ្ងៃសូមទៅទទួលការការព្យាបាលរបស់វេជ្ជបណ្ឌិត។

⊙ករណីមានប្រតិកម្មអាឡែហ្សីធ្ងន់ធ្ងរ(ប្រតិកម្មអាណាហ្វីឡាក់ទិច។ល។) អមដោយអាការៈ ពិបាកដកដង្ហើម, បាត់បង់ស្មារតី ឬហើមមុខ សូមទូរស័ព្ទទៅ ១១៩ភ្លាមៗ ឬទៅបន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត។

< បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧ - ១៣៦៦ >